**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តាងនាមប្រជារាស្ត្រខ្មែរ

**សាលាដំបូងខេត្តកណ្តាល**
សាលក្រមព្រហ្មទណ្ឌ
លេខៈ ០៤៤ (ឆ)
ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២

សាលាដំបូងខេត្តកណ្តាល បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល
លោក [redacted] ចៅក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល
លោក [redacted] ចៅក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល
លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អ៊ូជី

ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:**១៦៨៥**អក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] សុវណ្ណឆៃ ភេទប្រុស អាយុ ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិព្រែកល្វា ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ប៊ុនស្រៀង (រស់),ម្តាយឈ្មោះ [redacted] សុផាន (រស់) នៅលីវ ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី ១១.១០.២០២១)**

២.ឈ្មោះ [redacted] **អ៊ូជី** ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មុនពេលចាប់ខ្លួននៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ឃ្លាច (រស់),ម្តាយឈ្មោះ [redacted] ផា (ស្លាប់) នៅលីវ ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី ១១.១០.២០២១)**

៣.ឈ្មោះ [redacted] **រិទ្ធឌី** ហៅ ម៉េង ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មុនពេលចាប់ខ្លួននៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] គន្ធា (រស់), ម្តាយឈ្មោះ [redacted] ណោង (រស់) នៅលីវ ទោសពីមុនគ្មាន។ **(គេចខ្លួន)**

ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិសន្លុងឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា**៤០** និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ ឈ្មោះ [redacted] សុវណ្ណឆៃ ភេទប្រុស អាយុ ២១ឆ្នាំ បានទិញថ្នាំញៀនពីឈ្មោះ [redacted] រិទ្ធឌី ហៅម៉េង ចំនួន ០៤កញ្ចប់ក្នុងតម្លៃ ២០០ ០០០រៀល ដើម្បីយកទៅលក់បន្ត។

លុះដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២១ ឈ្មោះ [redacted] អ៊ូជី បានទិញថ្នាំញៀនបន្តពីឈ្មោះ [redacted] សុវណ្ណផៃ ចំនួន ០១ កញ្ចប់ ក្នុងតម្លៃ ៧០ ០០០រៀល ដើម្បីយកទៅលក់បន្តទៀត រួចសមត្ថកិច្ចក៏ចុះសហការណ៍ជាមួយកម្លាំងនគរបាលប៉ុស្តិ៍សន្លុង ស្រុកខ្សាច់កណ្តាល បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] អ៊ូជី និងដកហូតថ្នាំញៀនបានចំនួន ០១ កញ្ចប់តូច និងសម្ភារៈសម្រាប់ប្រើប្រាស់ និងបន្តឃាត់ខ្លួនឈ្មោះ [redacted] សុវណ្ណផៃ ដកហូតបានថ្នាំញៀនចំនួន ០២កញ្ចប់តូច និងសម្ភារៈសម្រាប់ប្រើប្រាស់ ថ្នាំញៀនមួយចំនួន។

## បានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខៈ ០៥១ ដកសព ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-ដីកាដំណោះស្រាយលេខៈ ១០៣ ដកដស ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

-ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១៥៣ ដកចត/២២ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## នាពេលសវនាការ

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារទាំងអស់ក្នុងសំណុំរឿង

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

## សំអាងហេតុ

១-តុលាការបានទទួលបណ្តឹងតាមដីកាដំណោះស្រាយលេខៈ ១០៣ ដកដស ចុះថ្ងៃទី២១ ខែ មករា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សុវណ្ណផៃ , ឈ្មោះ [redacted] អ៊ូជី និងឈ្មោះ [redacted] រិទ្ធឌី ហៅម៉េង មកតុលាការដើម្បីជំនុំជម្រះ ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមអង្គហេតុបានបញ្ជាក់ថា កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ ស្ថិតនៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ពិតជាកើតមាននូវអំពើ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណផៃ , ឈ្មោះ [redacted] អ៊ូជី និងឈ្មោះ [redacted] រិទ្ធឌី បានធ្វើសកម្មភាព លក់ ទិញ និងប្រើប្រាស់ថ្នាំញៀន ។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណផៃ បានឆ្លើយថា៖ មុនថ្ងៃកើតហេតុ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ [redacted] រិទ្ធឌី ចំនួនបួនកញ្ចប់តូច ដើម្បីយកមកលក់ ។ លុះដល់ថ្ងៃកើតហេតុ ខ្លួនបានប្រើប្រាស់ថ្នាំញៀនអស់ចំនួនមួយកញ្ចប់តូច និងបានយកថ្នាំញៀននេះទៅលក់ឲ្យគេចំនួន ០១ កញ្ចប់ ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ូជី បានឆ្លើយថា៖ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនអស់រយៈពេលជាងមួយឆ្នាំមកហើយ បន្ទាប់មកខ្លួនក៏ចាប់ផ្តើមលក់ដូរថ្នាំញៀន ។ នៅថ្ងៃកើតហេតុ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ [redacted] សុវណ្ណផៃ ចំនួន ០១កញ្ចប់ តម្លៃ ៧០ ០០០រៀល យកមកវែកជាកញ្ចប់តូចដើម្បីលក់បន្ត ដោយលក់ក្នុងមួយកញ្ចប់តម្លៃ ២០០០០រៀល ។ ឃើញថា ចម្លើយទាំងនេះគឺជនជាប់ចោទបានឆ្លើយសារភាពពីអំពើប្រព្រឹត្ត



Scanned with CamScanner

ល្មើសរបស់ខ្លួន ដែលចម្លើយនេះអាចឲ្យតុលាការជឿបាន ព្រោះថា ចម្លើយមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងថ្នាំញៀនដែលបានដកហូតជាក់ស្តែង ។

៤-ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី បានរត់គេចខ្លួនបាត់ក្រោយពេលប្រព្រឹត្តបទល្មើស ហើយចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជននេះជននេះដើម្បីបំភ្លឺការពិត ។

៥-ទាំងចម្លើយរបស់ជនជាប់ចោទ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងជាឯកសារពាក់ព័ន្ធ មានភាពស៊ីសង្វាក់គ្នា ដែលកំណត់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន ។

៦-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៧-អំពើប្រព្រឹត្តជនជាប់ចោទគឺមានចេតនា ទិញ លក់ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលថ្នាំញៀនជាប្រភេទមេតំហ្វេតាមីន មានបរិមាណទម្ងន់ស្មើនឹង ០,៨៣ក្រាម ដែលអំពើនេះច្បាប់កំណត់ថាជាបទព្រហ្មទណ្ឌ និងមានចែងក្នុងបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-ជនជាប់ចោទជានីតិជន ហើយមិនមានភស្តុតាងឬសញ្ញាណណាបញ្ជាក់ថា កើតមានវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើប្រព្រឹត្តរបស់ខ្លួន ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណឆៃ** , ឈ្មោះ [redacted] **អ៊ូជី** និងឈ្មោះ [redacted] **ទ្ធី** ដែលមានសាវតាជាតិដូចខាងលើ ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១០-គប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] អ៊ូជី ក្នុងកំរិតដាក់ពន្ធនាគារ ១ឆ្នាំ និងឈ្មោះ [redacted] សុវណ្ណឆៃ , ឈ្មោះ [redacted] រិទ្ធី ក្នុងកំរិតដាក់ពន្ធនាគារ ២ឆ្នាំ ដោយពិចារណាទៅលើលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទដូចខាងក្រោម:

-អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណ: និងរបៀបរៀបរយសង្គម ។

-សកម្មភាពល្មើសពុំបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរឡើយ ។

-ជនជាប់ចោទបានឆ្លើយសារភាព ។

-ថ្នាំញៀនមានចំនួនតិចតួច ។

-ជនជាប់ចោទឈ្មោះ [redacted] អ៊ូជី គិតមកត្រឹមថ្ងៃប្រព្រឹត្តបទល្មើស មានអាយុត្រឹមតែ ១៧ឆ្នាំប៉ុណ្ណោះ គឺជាអនីតិជន ដោយយោងតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ អប្បបរមានិងអតិបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្តាល ។ មូលហេតុទាំងនេះនាំឲ្យតុលាការ ពិចារណាប្រកាសទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ ។

១១-ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី មានកំរិតទោសចាប់ពី ១ឆ្នាំ ដោយគ្មានការព្យួរទោស ហើយជននេះបានរត់គេចខ្លួន ក្រោយពេលប្រព្រឹត្តបទល្មើស និងមានភស្តុតាងច្បាស់លាស់ថា ជននេះពិតជាបានប្រព្រឹត្តបទល្មើស ។ ហេតុនេះតុលាការគប្បីចេញដីកាបង្គាប់ចាប់ខ្លួនជននេះ និងយកមកឃុំក្នុងពន្ធនាគារតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

១២-វត្ថុតាងគប្បីសម្រេចរឹបអូសរួមមាន៖ ម្សៅក្រាមពណ៌សថ្លាជាសារធាតុញៀន ប្រភេទ(ម៉ាទឹកកក) ចំនួន០៣កញ្ចប់ (បី) មានទម្ងន់ស្មើរនឹង ០,៨៣ក្រាម , ទូរស័ព្ទដៃម៉ាក NOKiA ចំនួន ០១ គ្រឿង (មិនប្រក្រតី) និង សម្ភារៈសម្រាប់ប្រើប្រាស់សារធាតុញៀនមួយចំនួន ។

១៣-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទបានឆ្លើយសារភាពទទួលស្គាល់នូវទង្វើប្រព្រឹត្តរបស់ខ្លួន ដែលចម្លើយសារភាពនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ ។ រក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ:០៥១ ដកសព ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល និងស្នើសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។ តុលាការយល់ស្របនឹងសេចក្តីសន្និដ្ឋាននេះ ។

១៤-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់៖ កូនក្តីខ្លួនបានឆ្លើយសារភាពទទួលកំហុសរបស់ខ្លួន តាំងពីដំណាក់កាលដំបូងនៃនីតិវិធី ម្យ៉ាងទៀតកូនក្តីខ្លួនជាអនីតិជនទៀតផង ហេតុនេះសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន ដោយយោងតាមមាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ ។ គប្បីតុលាការពិចារណា ។

១៥-សម្តីចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំឲ្យតុលាការបន្ធូរបន្ថយទោស។ គប្បីតុលាការពិចារណា ។

**សម្រេច**

**១**-ផ្តន្ទាទោសជនជាប់ចោទ៖

១.១.ឈ្មោះ [redacted] សុវណ្ណនៃ ភេទប្រុស អាយុ ២១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិព្រែកល្វា ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ប៊ុនស្រៀង (រស់),ម្តាយឈ្មោះ [redacted] សុផាន (រស់) នៅលីវ ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី ១១.១០.២០២១)**

១.២.ឈ្មោះ [redacted] **រិទ្ធីឌី** ហៅ ម៉េង ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មុនពេលចាប់ខ្លួននៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] គន្ធា (រស់), ម្តាយឈ្មោះ [redacted] ណេង (រស់) នៅលីវ ទោសពីមុនគ្មាន។ **(គេចខ្លួន)**

ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈ ០២(ពីរ)ឆ្នាំ ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១.៣.ឈ្មោះ [redacted] **អ៊ុជី** ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មុនពេលចាប់ខ្លួននៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ឃ្លាច (រស់),ម្តាយឈ្មោះ [redacted] ផា (ស្លាប់) នៅលីវ ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី ១១.១០.២០២១)**

ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ ពីបទ៖ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២**-បង្គាប់ឲ្យចាប់-ឃុំខ្លួនឈ្មោះ [redacted] **រិទ្ធីឌី** ដែលមានសាវតាជាតិដូចខាងលើ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។



Scanned with CamScanner

៣-វត្ថុតាងត្រូវរឹបអូសមាន៖ ម្សៅក្រាមពណ៌សថ្លាជាសារធាតុញៀន ប្រភេទ(ម៉ាទឹកកក) ចំនួន ០៣កញ្ចប់(បី) មានទម្ងន់ស្មើរនឹង ០,៨៣ក្រាម , ទូរស័ព្ទដៃចំនួនមួយគ្រឿង ម៉ាកណូគា (មិនប្រក្រតី) និងសម្ភារៈសម្រាប់ប្រើប្រាស់សារធាតុញៀនមួយចំនួន ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ឈ្មោះ [redacted] សុវណ្ណដៃ , ឈ្មោះ [redacted] អ៊ូជី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រិទ្ធឌី បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ |

[redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥

ខេត្តកណ្តាល, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner